# រឿង៖ បងប្រុសម្នាក់នេះ ស្លាប់បាត់ហើយ

## ភាគទី២

«ខ្ញុំសូមទៅមើលគេផងបានដែរ?!»

ស្ងួរទាំងដកដង្ហើមវែង ព្រោះខ្ញុំតែងកើតសភាពចង់ដង្ហក់ រាល់ពេលដែលនិយាយពី«គេ»ជាមួយអ្នកផ្សេង។

គិលានុបដ្ឋាកម្នាក់នេះ ដូចជាមិនយល់នៅឡើយទេថា ខ្ញុំកំពុងនិយាយអំពីអ្នកណា ?

ដឹងចិត្តគាត់ខ្ញុំចាប់ផ្ដើមផ្ដួន៖

«អ្នកជំងឺស្រីម្នាក់ដែលខ្ញុំត្រូវបរិច្ចាគក្រលៀនឱ្យគេនោះ!»

ឃើញគេនៅទើរ ខ្ញុំបន្ថែម៖

«ជំទាវសាមីន!»

គេសម្លឹងខ្ញុំ។ ក្នុងពន្លឺភ្នែករបស់គិលានុបដ្ឋាករូបនេះ ធ្វើឱ្យខ្ញុំកាន់តែមានអារម្មណ៍តឹងតែងនិងវាយតម្លៃបានថា នាងទំនងជា មិនទាន់ស្ថិតនៅក្នុងស្ថានភាពសុខសប្បាយ ឬធានាអ្វីបាននៅឡើយ។

តើនាងបានដំណឹងពីការបរិច្ចាគសរីរាង្គរបស់ខ្ញុំទេ?

ខ្ញុំគិតដោយម្នាក់ឯង។

«គាត់នៅសន្លប់បង!»

«ខ្ញុំអត់ធ្វើអីទេ ខ្ញុំគ្រាន់តែសុំទីមើលគេពីក្រៅ!»

គិលានុបដ្ឋាកនោះដំអក់បន្តិច ទើបនិយាយមកកាន់ខ្ញុំ៖

«ខ្ញុំជួយសួរលោកដុកទ័រឱ្យ!»

«បាទ! អរគុណ»

ទីបំផុតខ្ញុំក៏បានទទួលការអនុញ្ញាតឱ្យឡើងទៅកាន់ជាន់ខាងលើដើម្បីជួបគេ។ នៅតាមរបៀងជណ្តើរមន្ទីរពេទ្យ ខ្ញុំឡើងមួយៗទាំងពិចារណាបណ្តើរ ទៅដល់រឿងហេតុទាំងអស់ដែលបានកើតឡើងចំពោះពួកយើង។

ឬមួយនេះ ជាលទ្ធផលចុងក្រោយសម្រាប់ខ្ញុំហើយនឹងគេ? សរីរាង្គមួយរបស់ខ្ញុំបានទៅនៅក្នុងរាងកាយគេហើយជួយគេឱ្យក្រោកមកវិញបាន តែអ្វីទៅនឹងអាចជួយគេឱ្យញញឹមឡើងវិញបាន?

ចិត្តខ្ញុំមិនដែលស្គាល់ ស្ងប់នោះទេចាប់តាំងពីដឹងថាគេឈឺ។

កាលពីមុនយើងនៅក្មេង យើងរៀននៅសាលា សម្រាប់ខ្ញុំ ពាក្យថាសន្តិភាពផ្លូវចិត្តគឺមានន័យស្មើពេលវេលាដែលគ្មានសង្គ្រាម គ្មានប្រយុទ្ធ វាយតប់ និងអំពើហិង្សា តែក្រោយមក សន្តិភាពចិត្តខ្ញុំសំដៅទៅលើភាពសុខសាន្តរបស់គេ។

ភាពស្ងប់ស្ងាត់នៅមន្ទីរនេះ បានធ្វើឱ្យខ្ញុំនឹកឃើញដល់ពាក្យខ្លះៗនៃបណ្តាសៀវភៅដែលខ្ញុំបានអាន។ ពាក្យមួយលើកឡើងថា ជីវិតនិងដំណាក់កាលទាំងអស់របស់វា គឺជាការពិសោធន៍! ឆ្លងកាត់ការពិសោធន៍កាន់តែច្រើនយើងនឹងកាន់តែរឹងមាំឡើង? ចុះហេតុអ្វីបានជាថ្ងៃនេះ ខ្ញុំហត់ម្ល៉េះរាល់ពេលនឹកដល់បណ្តាបទពិសោធន៍អស់ទាំងនោះ?

មិនយូរប៉ុន្មាន មានស្នូរជើងលើជណ្តើរ។

ពីដំបូងខ្ញុំឃើញមនុស្សម្នាក់ ដែលខ្ញុំមិនចង់ឃើញ! គេនេះមានទឹកមុខស្រពោនអមដំណើរដោយ មនុស្សស្រីម្នាក់និងប្រុសម្នាក់តាមមក ទំនងជាស្ទីលរបស់ពួកអ្នកមាន ដែលតែងតែមានជំនួយការឬលេខាមកតាមហែហូរ។

តែចំពោះមុខ ទោះបីម្នាក់នេះ មានអំណាច មានលុយប៉ុន្មាន ក៏នៅមិនអាច ចៀសផុតពីបញ្ជូនប្រពន្ធសំណព្វចិត្តមកកាន់ទីកន្លែងនេះដដែល។

ខ្ញុំមិនចង់និយាយជាមួយម្នាក់នេះទេ បានជាងាកមុខចេញ។

«បងម៉ឺន!»

ម្នាក់នេះ ហៅខ្ញុំហើយឈប់ជើង ធ្វើឱ្យក្រុមបរិវារក៏ឈប់ជើងតាម។ នេះគឺមនុស្សឈ្មោះម៉ាចដែលខ្ញុំធ្លាប់ចិញ្ចឹម ហុចចំណីតាមរយៈច្រកចម្រឹងបង្អួចកាលពីជិត២០ឆ្នាំមុន។

ជារៀងរាល់ថ្ងៃខ្ញុំ មិនដែលបោះបង់វាចោលព្រោះខ្ញុំខ្លាចវាភ័យស្លុត ដែលត្រូវជាប់ក្នុងផ្ទះម្នាក់ឯង ហើយសូម្បីតែយប់ៗឡើង ខ្ញុំទៅអង្គុយឱ្យមូសចោមនៅក្រោមបង្អួចនោះចាំទៀត ទម្រាំម្ដាយម៉ាចមកដល់។

ដើម្បីការពារកុំឱ្យវាត្រូវចាក់សោជាប់ក្នុងទ្រុងនោះបន្ត ខ្ញុំត្រូវធានានឹងម្ដាយវាថានឹងនាំវាតាមខ្លួនគ្រប់ទីកន្លែងដូចស្រមោលអន្ទោលតាមប្រាណ។ ទីបំផុត នៅពេលដែលម្ដាយស្លាប់ ហើយអាម៉ាចត្រូវបានទៅកាន់មណ្ឌលកុមារកំព្រា ខ្ញុំតាមស៊ើបពីវារហូតដល់ដឹងថាវាត្រូវគេធ្វើបាបស្ដមរីងរៃព្រោះមិនចេះសម្រប និងមិនព្រមញ៉ាំបាយ។

ចុងក្រោយដោយសារតែចង់តាមមើលលួងលោមវា ខ្ញុំសុខចិត្តទទួលខ្លួនយកពេលទំនេររត់ដឹករ៉ឺម៉ក់គីឡូ ទៅជួយធ្វើការជាមួយមេចុងភៅនៅក្នុងមណ្ឌលនោះ ឆ្លៀតរៀនភាសាអង់គ្លេសនៅទីនោះ និងធ្វើយ៉ាងណាក៏ដោយ ឱ្យវាបានឃើញខ្ញុំជារៀងរាល់ថ្ងៃ ហើយព្រមរៀនព្រមញ៉ាំបាយ។

មុននេះប្រមាណពីរបីខែ វាបានមករកខ្ញុំដោយខឹងសម្បាហើយ ហៅខ្ញុំថា«ឯង» ជំនួសឱ្យពាក្យ«បង» ព្រោះវានឹកខឹងរឿងចាស់របស់ខ្ញុំនឹងអាមីន។

ថ្ងៃនេះម៉ោងនេះ បៀបដែលវាប្ដូរពីពាក្យ ហៅខ្ញុំថា«ឯង» មកជា«បង»ដូចមុនវិញ ប្រហែលជាទុក្ខវេទនាថ្មីនេះ ប្ដូរចរិតឱ្យវា ឈប់ខែងរ៉ែង ឈប់អស្ចារ្យ ឈប់រមិលគុណ ហើយឈប់តុកស៊ិក។

ខ្ញុំមិនខ្វល់ទេ! ខ្ញុំបានតាំងចិត្តថា មិនស្គាល់វា តាំងពីថ្ងៃដែលខ្ញុំបានប្រាប់វាថា បងវា អាម៉ឺនកាលពីម្ភៃឆ្នាំមុន ស្លាប់បាត់ហើយ ហើយខ្ញុំមកទីនេះដើម្បីអាមីន មិនមែនដើម្បីវាឡើយ។

ពេលខ្ញុំងាកមុខចេញហើយបន្តដើរឡើងទៅ វាខាំមាត់និយាយបញ្ឈឺខ្ញុំ៖

«កុំភ្លេចថា បើកុំតែខ្ញុំមើលថែបងឯង បងឯងរលាកស្រោមខួរស្លាប់យូរហើយ!»

កោតតែលើកនេះ វានៅចង់រំឭករឿងចាស់យកមកទូទាត់គ្នាជាមួយខ្ញុំទៀត?

ឃើញខ្ញុំបញ្ឈប់ដំណើរធ្វើឱ្យ ពួកអ្នកតាមហែរហមរបស់អាម៉ាចរត់ចេញអស់ទៅ ដូចចង់ទុកឱ្យពីរនាក់អតីតបងប្អូនបានសើរើដំបៅដែលនៅមិនទាន់សះ។

កាលមកជួយធ្វើការជាមួយមីងចុងភៅនៅមជ្ឈមណ្ឌល ដើម្បីបានលេសឆ្លៀតតាមដានអាម៉ាចនិងលួងលោមវាដើម្បីឱ្យព្រមបន្តការរៀនសូត្រ ខ្ញុំក៏ឆ្លៀត បានរៀនភាសាអង់គ្លេសដោយមិនគិតថ្លៃនៅក្នុងមជ្ឈមណ្ឌលនោះផងដែរ។

ថ្ងៃមួយនៅពេលដែលខ្ញុំត្រូវប្តូរផ្ទះទៅដីថ្មីនៅកំពង់ចាមបានប្រហែល២សប្តាហ៍ ពេលនោះ ខ្ញុំបានឮដំណឹងថា អាមីនក៏ត្រូវបានបញ្ជូនមកកាន់មជ្ឈមណ្ឌលដូចគ្នាជាមួយម៉ាច ដោយសារនាងព្យាយាមរត់ចេញពីផ្ទះហើយត្រូវឪពុកម្តាយចិញ្ចឹមតាមចាប់បានច្រើនសា។

ពួកគេប្រើអំពើហិង្សាទៅលើនាងរហូតដល់អ្នកភូមិផ្សេងទៀតអ្នករាយការណ៍ទៅសមត្ថកិច្ច ចុងក្រោយសមត្ថកិច្ចក៏បានសម្រេច បញ្ជូននាងឱ្យទៅរស់នៅមជ្ឈមណ្ឌល។

យប់នោះខ្ញុំសប្បាយចិត្តខ្លាំងពេក ក៏ព្យាយាមសុំម្តាយវិលមកភ្នំពេញវិញនៅព្រឹកបន្ទាប់។ ប៉ុន្តែដោយសារតាមផ្លូវមានភ្លៀងធ្លាក់ខ្លាំង ហើយខ្ញុំសុំដោយសារម៉ូតូរបស់អ្នកដែលត្រូវមកភ្នំពេញទិញទំនិញ ខ្ញុំត្រូវទទឹកជោកភ្លៀងច្រើនម៉ោងបណ្តាលឱ្យ គ្រុនសន្ធំនៅយប់នោះ គេងនៅផ្ទះបាយមជ្ឈមណ្ឌល មិនមានអាចវិលទៅកំពង់ចាមបាន។

អាមីន ទើបតែចូលមករស់ក្រោមការគ្រប់គ្រងក្នុងមជ្ឈមណ្ឌលនេះ នាងមិនមានទំនាក់ទំនងល្អជាមួយគ្រូ ហើយថែមទាំងមិនស្គាល់គេ មិនអាចគេចចេញពីបន្ទប់ទេ មានតែម៉ាចដែលអាចមើលថៃទាំខ្ញុំពេញមួយយប់នោះតែពីរនាក់បងប្អូនម៉ង់ៗ។

វាស្ងំទឹកឱ្យខ្ញុំ និងឱ្យថ្នាំខ្ញុំលេប ព្រមទាំងបញ្ចុកបបរឱ្យខ្ញុំ។ ហើយនៅថ្ងៃស្អែកឡើងវាបាននំប៉័ងមកឱ្យខ្ញុំតាមដែលខ្ញុំទាមទារ ចុងក្រោយជំងឺរបស់ខ្ញុំបានជាសះស្បើយនៅក្រោមដៃថៃទាំរបស់ប្អូនប្រុសខ្ញុំម្នាក់នេះ។

«សូម្បីតែបងម្តាយបងឯងឈឺ ក៏ខ្ញុំជាអ្នកយកលុយរង្វាន់សិស្សពូកែ យកឱ្យបងឯងទិញថ្នាំដែរ!»

ម៉ាចរំឭកទៀត គឺរំឭកបណ្តាគុណូបការៈ ដែលវាបានធ្វើមកលើខ្ញុំបន្ថែម តែមាត់វាដដែលនេះមិនដែលនឹកឃើញរំឭកការលះបង់ធំៗ ដែលខ្ញុំបានធ្វើឡើងដើម្បីវាវិញនោះទេ។

កាលណោះក្រោយពីខ្ញុំបានជាសះពីគ្រុន ដល់ម៉ែខ្ញុំធ្លាក់ឈឺម្តង។ ម្តាយខ្ញុំមិនឈឺស្រាលដូចខ្ញុំទេ។ គាត់មានរោគទឹកនោមផ្អែម ហើយគេចវេះមិនព្យាបាលធ្វើមិនដឹងមិនឮយូរមកហើយ រហូតចុងក្រោយគាត់ចាប់ផ្តើមធ្ងន់។

«ឈប់រៀនហើយ! ត្រូវយកម៉ែមកមើលនៅភ្នំពេញនេះ! មិញទៅជួបមីង មេចុងភៅ គាត់ប្រាប់ថា បើចង់រស់នៅក្នុងមណ្ឌលនេះ ត្រូវចូលធ្វើការពេញម៉ោង អ៊ីចឹងបងបានចូលធ្វើការនៅណោះហើយ ជាសន្តិសុខយាមផង ជាអ្នកសម្អាតសួនផង ជួយដាំបន្លែ ជួយការងារនៅចង្ក្រានរបស់គាត់ផង!»

ខ្ញុំអង្គុយក្រោមដើមជ្រៃក្រឹមត្រឈៃមួយ និយាយឈ្មោះអាមីន។ អង្គុយនៅទីនោះបានក្លាយជាទម្លាប់ទៅហើយ ពិសេសនៅក្រោយពេលអាហារពេលល្ងាច បន្ទាប់ពីចប់ការងារផ្សេងៗ នាងតែងតែមកជួយលាងចានជាមួយខ្ញុំហើយនិងប្រមូលសំរាមសម្អាតផ្ទះបាយជាមួយគ្នា។

អ្នកនៅក្នុងមណ្ឌលនេះ សុទ្ធតែដឹងថាអាមីនជាប្អូនស្រីរបស់ខ្ញុំ ប៉ុន្តែអាម៉ាចវិញ មិនសូវមានមុខទេដោយសារវាចូលចិត្តមើលទូរទស្សន៍ជាមួយគ្រូៗ តាមទម្លាប់សិស្សពូកែ មានគ្រូនិងប្រធានមជ្ឈមណ្ឌលស្រលាញ់ថ្នាក់ថ្នម។

ទោះយ៉ាងណាខ្ញុំនិងអាមីនតែងតែមានទោមនស្សជាមួយម៉ាច ពីព្រោះវាជាក្មេងដែលរៀនពូកែខ្លាំងតែងតែទទួលបានលិខិតសរសើរផ្ញើមកដល់មជ្ឈមណ្ឌលពីសាលារដ្ឋ ផ្ទុយគ្នាពីសាមីនដែលមកដល់មជ្ឈមណ្ឌលនេះពេលអាយុច្រើននាងហួសទៅហើយទើបតែបានចូលសាលានឹងគេ។

ទោះបីជាកាលពីក្មេង នាងចេះព្យញ្ជនៈនិងស្រៈព្រមទាំងអក្សរខ្លះដែលខ្ញុំបានបង្រៀនប៉ុន្តែនៅតែ មិនអាចរៀនតាមគេទាន់ ដូច្នេះនាងបាននិយាយនឹងខ្ញុំថា នៅពេលបានអាយុដប់ប្រាំមួយឆ្នាំ នាងចង់សុំគេឈប់រៀនហើយចូលទៅសិក្សាជំនាញវិញ។

«ជំនាញអីទៅ ដែលអាមីនឯងចង់ធ្វើ?!»

«ខ្ញុំចង់ធ្វើការនៅហាងបារាំងព្រោះខ្ញុំចេះធ្វើម្ហូប តែគ្រូថាយើងនៅក្មេងអាចក្លាយជាអ្នករត់តុសិន!»

«ធ្វើជាអ្នករត់តុមានអីល្អទៅ? ទៅឈររហូតហ្នឹង! ឮអ្នកមុនៗគេនិយាយថា ត្រូវឈររហូតទាល់តែភ្ញៀវចេញអស់ពីក្នុងហាង មិនអាចទៅណាបានទាំងអស់!»

តែគេមិនបានឈប់ត្រឹមណោះនៅតែតវ៉ាជាមួយខ្ញុំវិញ៖

«ត្រឹមតែឈរមានអីពិបាកទៅ?!»

ខ្ញុំមិនចង់និយាយប្រាប់គេត្រង់ៗថា គេជាស្រីមានសម្រស់ស្អាតដូច្នេះ ខ្ញុំមិនចង់ឱ្យគេទៅឈរហើយត្រូវពួកនោះលួកលាន់ ដូចកាលដែលខ្ញុំឮអ្នកជិតខាងនិយាយអំពីម្ដាយខ្ញុំទេ។ ម្ដាយខ្ញុំគាត់ធ្វើជាអ្នកឡង់សេស្រាបៀរ មកផ្ទះជូនកាលអង្គុយយំ និងត្រូវមីងស្រស់ក្បែរផ្ទះមកសួរនាំ ខ្ញុំលួចស្ដាប់ឮគាត់ត្អូញពីរឿងប្រុសៗលូកលាន់បំពានគាត់។

ប៉ុន្តែខ្ញុំមិននិយាយទុក្ខនេះចេញមកជាមួយអាមីនទេ។ ខ្ញុំទើបតែដឹងខ្លួនឯងក្នុងពេលនោះថា ក្នុងចិត្តខ្ញុំមានកូនចិត្តមួយ ដូចចេះប្រចណ្ឌជាមួយគេ ហើយខ្ញុំមិនចង់ឱ្យគេទៅធ្វើការនៅភោជនីយដ្ឋាននោះទេ។

«អត់សប្បាយចិត្តហ្មេន! បើបងឯងមិនចង់ឱ្យខ្ញុំធ្វើការនៅភោជនីយដ្ឋាន ខ្ញុំធ្វើអីផ្សេងក៏បានដែរ!»

«ធ្វើអីផ្សេងទៅ?»

ខ្ញុំសួរទៅកាន់គេវិញដោយសប្បាយចិត្ត។ ពេលនោះយើងទើបតែមានវ័យជំទង់ ខ្ញុំបងនាងប្រាំឆ្នាំមិនមែនដោយខ្ញុំអាយុដប់ប្រាំពីរឆ្នាំ នាងទើបអាយុដប់ពីរឆ្នាំ ប៉ុន្តែអាមីនដូចជាចាស់ទុំស្មើស្រីក្រមុំអាយុ១៦ឆ្នាំ។ នាងតែងតែគិតអំពីអនាគតរបស់ខ្លួនឯង។

«ខ្ញុំរៀនកាត់សក់ក៏បាន!»

គេមិនចូលចិត្តការងារសម្រស់ទេ ព្រោះគេពូកែធ្វើម្ហូបតែគេសម្រេចចិត្តនេះព្រោះតែខ្ញុំហាមមិនឱ្យគេធ្វើការនៅហាងបារាំង។

នៅថ្ងៃមួយ ពេលដឹកកង់ជូនគេត្រឡប់មកពីការងារហ្វឹកហាត់នៅហាងសាឡនក្បែរផ្សារចម្ងាយប្រមាណជាង ៣គីឡូម៉ែត្រពីមជ្ឈមណ្ឌល ខ្ញុំបានទាន់សភាពបុរសអ្នកមានម្នាក់ដែលកំពុងមានគ្រោះថ្នាក់។

ពូនោះតែងតែមានធុរៈក្បែរៗខាងត្បូងមជ្ឈមណ្ឌល ប៉ុន្តែថ្ងៃនោះ ដៃគូគំនុំបញ្ជារកស៊ីរបស់គាត់បានស្ទាក់មកប្រទូសរ៉ាយ។ គាត់មានតែម្នាក់ឯង ឯខាងគេមាន៣នាក់។ ប៉ុន្តែខ្ញុំបានមកឃើញទាន់ម៉្លោះហើយ ខ្ញុំក៏សម្រេចចិត្តថាជួយគាត់។

ពេលនោះខ្ញុំត្រូវគេចាក់នឹងកាំបិត ហើយដេកដួលឈាមល្ហាច។

វាល្អដែរ ដែលអាមីនបានរត់ទៅហៅអ្នកផ្សេងមកពេលខ្ញុំដេញនាងឱ្យទៅមណ្ឌលមុន។

ស្នាមកាំបិតលើខ្នងខ្ញុំ លើខ្លួនខ្ញុំ មិនមែនជារឿងថ្មីទេ។ ពេលខ្ញុំពេញវ័យនៅភូមិជើងចាប ការវាយតប់និងតស៊ូដោយហិង្សាកម្លាំងបាយ ខ្ញុំបានឆ្លងកាត់សន្លប់ដេកដួលម៉ែដឹកទៅព្យាបាលជាញឹកញាប់។ មិនមែនខ្ញុំជាមនុស្សហិង្សា តែខ្ញុំកើតឡើងក្នុងជំរំមួយដែល មានតែកម្លាំងបាយទេដែលអាចការពារយើងបាន។

ជាធម្មតា យើងចង់គេចបញ្ហាតែបញ្ហាមករកយើងដល់មាត់ទ្វារ។ ពួកអ្នកលក់ដូរគ្រឿងញៀន ថ្នាំសម្រើបចង់បានក្មេងប្រុសៗដូចយើងឱ្យទៅចូលក្រុមជាមួយពួកគេ តែខ្ញុំជាក្មេងនៅរៀននិងម្ដាយខ្ញុំតាមដានដិតដល់ ខ្ញុំតែងតែយល់ច្បាស់អំពីអន្ទាក់របស់ពួកគេដូច្នេះលួងលោមមិនបាន ពួកគេបានប្រើវិធីបង្ខំ។

ទម្រាំបានចាកចេញពីទ្រនំជើងចាប ឆ្ងាយពីជម្រកគ្រឿងញៀនស្រវឹង ខ្ញុំនេះសុំណាស់ទៅ ហើយជាមួយការវាយតប់គ្នា រត់កាត់ជឿងហែម ហក់ផ្លោះរបងរបួសពេញខ្លួន ស្នាមជើងធាក់ផ្ទប់ស្នាមដាវ និងកាំបិត។

លើកនេះ ខ្ញុំប្រថុយធ្វើជាHeroជួយពូនេះព្រោះខ្ញុំមិនដាច់ចិត្តធ្វើជាមិនឃើញ ព្រោះគាត់មើលទំនងជាមនុស្សស្លូតផង តែងជួយបរិច្ចាគ មីកញ្ចប់ និងនំ អង្ករដល់មណ្ឌលជារឿយៗ។

ប្រសិនគាត់មិនមែនមានផ្ទះក្បែរៗនេះ ប្រហែលជាក្រុមហ៊ុនគាត់ក្បែរៗនេះ។

ផុតពីគ្រោះថ្នាក់ គាត់ចង់សងគុណខ្ញុំដោយហៅខ្ញុំ ឱ្យទៅរស់នៅជាមួយគាត់ តែខ្ញុំបានសារភាពប្រាប់ថា ម្ដាយខ្ញុំឈឺខ្ញុំត្រូវចេញចូលមើលថែគាត់ ណាមួយជាក្មេងប្រុសខ្ញុំដល់វ័យត្រូវការសេរីភាពដើរហើរផង ខ្ញុំមិនទម្លាប់នៅក្រោមការគ្រប់គ្រងទេ។

ដូច្នេះពេលបានគាត់សួរថា តើខ្ញុំនៅមានប្អូនទេ? ខ្ញុំឆ្លើយថា មានប្អូនកំព្រាពីរនាក់ទៀត។ គាត់ថាគាត់អាចទទួលយកបានម្នាក់ ធ្វើជាកូន ដាក់ឱ្យសិក្សារៀនសូត្រគិតគូរអនាគតឱ្យ ដូច្នេះខ្ញុំបានសម្រេចចិត្តប្រគល់សាមីនឱ្យទៅគាត់។

រឿងនេះខ្ញុំមិនបានដឹងថា ម៉ាចបានទុកជាប្រធានបទសម្រាប់ខឹងខ្ញុំគុំគួនខ្ញុំ នោះឡើយ។

រហូតដល់ពេលមួយ វាបានទទួលអាហារូបករណ៍ចេញរៀនបន្តទៅប្រទេសអូស្ត្រាលី ទើបវាបានសរសេរលិខិតមួយមកប្រាប់ខ្ញុំថា វាអរគុណខ្ញុំណាស់ ដែលបានជ្រើសរើសយកសាមីនឱ្យទៅទទួលភ័ព្វព្រេងសំណាងជំនួសវា។

ជីវិតក្រោយៗមក បានបង្រៀនខ្ញុំថាយើងអាចបីបាច់ថែរក្សារាងកាយគ្នា តែយើងមិនស្គាល់ចិត្តគ្នាច្បាស់នោះឡើយ។ កុំថាឡើយយើងទុកគេជាប្អូន គិតដល់គេកម្រិតណា នៅតែមិនដែលគ្រប់ឡើយ ប្រសិនបើយើងបានធ្វើអ្វីមួយមិនត្រូវចិត្តគេ គេនឹងចិញ្ចឹមចិត្តចងចាំតែរឿងមួយនោះ។

ថ្ងៃនេះជួបគ្នាសាជាថ្មី វារំឭកឡើងមកវិញតែរឿងដែលវាបានជួយខ្ញុំកាលគ្រុនសន្និ និងរំឭកពីរឿងដែលវាយកលុយរង្វាន់សិស្សពូកែមកឱ្យខ្ញុំទិញថ្នាំ តែមិនដឹងថាតើវានៅចាំបណ្ដាថ្ងៃយប់ដែលខ្ញុំបានស៊ូអង្គុយក្រោមបង្អួចយាមវា និងធ្វើការងារសាលាជាមួយវា បង្រៀនវា ខណៈម្ដាយវាមិនដែលខ្វល់ មិនដែលគិតពីកូននោះ។

មនុស្សយើង ពាក្យថា គុណ១០០សំពៅទោសមួយចូលទៅ ពិតជារលត់គុណអស់ ឬមួយរឿងនេះកើតឡើងតែលើជំពូកមនុស្សរមិលគុណដូចវា?

សូម្បីតែមុនពេលចេញទៅបរទេស ម៉ាចសរសេរមកឌីដងខ្ញុំអ៊ីចឹងហើយ ខ្ញុំក៏នៅតែមិនទាន់ដឹងច្បាស់នៅឡើយថា មនុស្សម៉ាចនេះ មានរូបរាងជាកូនប្រុស ស្អាតបាត ឆ្លាតវៃ តែបែរជាមានឱបជាប់នូវផ្នត់គំនិត មានៈ ចងគំនុំ និង ច្រណែនឫស្យា តូចចិត្តតូចថ្លើម ប្រៀបធៀបច្រើន ខុសពីរូបរាងពិតរបស់វា។

រហូតដល់ព្រលប់មួយ ខ្ញុំបានចេញទៅជាមួយមេចុងភៅម្នាក់នៅសណ្ឋាគារផ្កាយប្រាំ ដែលគាត់ត្រូវគេជួលក្រៅឱ្យ រៀបចំកម្មវិធីហូបចុកអឹកអធិករបស់ពួកអភិជន ហើយគាត់ហៅខ្ញុំទៅជួយយកកម្រៃជាម៉ោង។

ពួកយើងកំពុងរៀបចំអាហារនៅសួន ស្រាប់តែមេការក្នុងផ្ទះ ចុះមកឡូឡាថាមានការវាយតប់ឈ្លោះប្រកែកគ្នាគប់ចានកែវនៅខាងលើផ្ទះ ដូច្នេះហើយពួកយើងត្រូវឡើងទៅរកសម្អាតមុនពេលម្ចាស់ផ្ទះខឹងសម្បា។ គ្មានអ្នកណាចង់ឡើងទៅនោះទេ ពួកអ្នកមានអស់នោះពេលស្រវឹងកាចៗខ្លាំងណាស់ ពេលខ្លះពួកគេគប់គ្នាត្រូវយើងជាអ្នកក្រនេះ ដេកពេទ្យអត់លុយមើលផងក៏មាន។ ណាមួយម្នាក់ៗគិតថា យើងមកបម្រើម្ហូបអាហារមិនមែនមកសម្អាតកែវចានដែលពួកគេវាយតប់គ្នានោះឡើយ ដូច្នេះហើយគ្មាននរណាព្រមឡើងទាំងអស់។

មេការរបស់ខ្ញុំភ័យព្រួយខ្លាចម្ចាស់ផ្ទះអន់ចិត្ត ដូច្នេះហើយជាការសងគុណគាត់ដែលតែងតែផ្ដល់ការងារម្ដងម្កាលមកឱ្យខ្ញុំ ខ្ញុំក៏បានលើកដៃព្រមស្ម័គ្រចិត្តឡើងទៅមើលឱ្យ។

ខ្ញុំឡើងទៅដល់ជាន់ខាងលើ។ ទីនេះពោរពេញទៅដោយការរៀបចំ ប្រៀបបីដូចជាស្ថានសួគ៌ភ្នែកស្រស់។ មនុស្សគ្រប់គ្នា ក៏តុបតែងកាយស្អាតសឹងមិនអាចព្រិចភ្នែកសម្លឹង។ ប្រុសៗរាងសង្ហាដូចទេវបុត្រ មនុស្សស្រីដូចជាទេពធីតា។ ខ្ញុំភ្លឹកភ្លាំងសម្លឹងពួកគេ ពីចម្ងាយ។

ខ្ញុំចាំបានថា ពេលនោះសំឡេងមួយគ្រោតគ្រាតលាន់មកស្រាលៗពីក្រោយខ្នងខ្ញុំ

«មិនប្រញាប់ធ្វើការ? ឈរនៅហ្នឹងធ្វើអី? ឡើងមកជាន់ហ្នឹងអ្នកណាអនុញ្ញាត? របស់របរនៅជាន់នេះសុទ្ធតែមានតម្លៃ! ចុះទៅក្រោមវិញទៅ!»

ធម្មតាច្រើនឆ្នាំមកនេះ ទទួលការប្រមាថ មាក់ងាយសង្ស័យពីក្រុមអ្នកមានលុយ មានអំណាច ខ្ញុំធ្លាប់អស់ទៅហើយ។ បើកុំតែសំឡេងនេះ ខ្ញុំដូចជាធ្លាប់ស្គាល់ ខ្ញុំច្បាស់ជាដើរចេញត្រុយមិនងាកទៅមើលពួកគេនោះទេ ព្រោះម្ដាយខ្ញុំតែងប្រាប់ «កុំឈ្លោះនឹងពួកអ្នកមាន យើងមិនដែលឈ្នះគេទេ! បើគេថាយើងលួច អ្នកផងនឹងមើលមកយើងដូចជាចោរមែន! បើគេថា យើងក្បត់ឬភូតភរ ក៏

អ្នកផងគិតថាទំនងភ្លាមដែរ ព្រោះតែក្លិនទឹកលុយ និងសម្បកក្រៅរបស់មនុស្ស បានគ្របពីលើគតិយុត្តិធម៌ក្នុងលោកនេះជាយូរណាស់មកហើយ!»

ខ្ញុំបែរក្រោយសន្សឹមៗទៅសម្លឹងក្នុងប្រស្រីនៃកែវភ្នែកមនុស្សប្រុសដ៏សង្ហាម្នាក់ ដែលកំពុងឈោងកចុចទូរសព្ទក្រោយពីបានបណ្ដេញប្រមាថកាតទានខ្ញុំ។

សម្រាប់ពួកគេ ជេរប្រមាថហើយ បែរទៅឈោងកចុចទូរសព្ទធ្វើដូចគ្មានអ្វីកើតឡើង ប្រហែលជាធម្មតាព្រោះអ្នកក្រដូចយើង គេទុកបញ្ចេញកំហឹងលេងដោយភ្លេចចោលវិញបានត្រឹមមួយប៉ប្រិចភ្នែកទាំងគេមិនដឹងទេថា ពាក្យពេចន៍សម្ដីរបស់គេ មួយៗបានចាក់របួសក្នុងបេះដូងរបស់យើង ឈឺយូរប៉ុណ្ណា?

ខ្ញុំធ្លាប់លួចរបស់គេហូប នោះគឺជារឿងកាលពីមុន គឺកាលពីខ្ញុំនៅក្មេង ដែលជាការលួចដើម្បីក្រពះខ្ញុំមិនដែលគិតចង់លួចឆក់របស់អ្នកណាម្នាក់ ដើម្បីទៅធ្វើជាអ្នកមានបាន ឬក៏ព្យាយាមកេងបន្លំ បោកបញ្ឆោត ចង់បានលើគំនរទុក្ខវេទនារបស់អ្នកណាឡើយ។

ទំនងឃើញខ្ញុំនៅជាប់ទ្រឹងដើរចេញមិនរួច ធ្វើឱ្យម្នាក់នោះដឹងខ្លួនងើបមុខមករកខ្ញុំដែរ។

ប្រហែលជាវានៅស្គាល់ខ្ញុំ បានជាអ្នកមានថ្មីម្នាក់នេះ ដូចជាថ្លោះទឹកមុខ ហើយទម្លាក់ដៃដែលកាន់ទូរសព្ទរាប់ពាន់ដុល្លាររបស់វា ចុះមកសន្សឹមៗ សម្លឹងខ្ញុំដោយក្ដីអៀនខ្មាស។

«បងម៉ឺន»

ខ្ញុំសើចចំអកតិចៗក្នុងចិត្តៈ

«ល្អហើយដែលឯងនៅស្គាល់ឈ្មោះអាបងប្រុសសំអុយរបស់ឯងម្នាក់នេះដែរ អាម៉ាច!»

៦ឆ្នាំដែលវាចាកចេញពីកម្ពុជា វាមិនដែលទាក់ទងមកទេ។ នៅមជ្ឈមណ្ឌល គ្មានអ្នកណាដឹងថាហេតុអ្វីឡើយ។ វាតែងតែងផ្ញើរបស់របរមកមីងប្រធាន និងមិត្តវាខ្លះដូចជា ស្គរសូកូឡា សំបុត្រ អាវយឺត។ល។ តែខ្ញុំ គឺសូន្យ។

មិននឹកស្មានថា ដោយសាររឿងខ្ញុំមួយគត់ គឺរឿងដែលខ្ញុំជ្រើសឱ្យអាមីនទៅនៅលើផ្ទះពូអ្នកមាននោះ អាម៉ាចសន្សំទុកថា នេះជាមូលហេតុ សម្រាប់អកតញ្ញូចំពោះខ្ញុំបានយូរដល់ពេលនេះ?

ខ្ញុំមិនចង់ធ្វើស្គាល់គ្នាជាមួយវាទេ ដោយសារឆ្អែតចិត្ត ទោះណាជាចិត្តមួយទៀតខ្ញុំនឹកវាយ៉ាងណាក្តី។ វានៅតែជាប្អូនតូចច្រម៉ក់ម្នាក់ ដែលកាលគ្រាមួយ ខ្ញុំតែងការពារ និងដឹកដៃទៅរៀនជាមួយគ្នា អង្គុយចាំម្តាយវាក្រោមបង្អួចជាមួយគ្នា។

តែពេលនេះ អតីតកាលមិនអាចយកមកនិយាយនាំតែបង្កើនការចងចាំដែលគ្មានន័យ។ ហើយខ្ញុំក៏មិនចង់ឱ្យអ្នកណាម្នាក់ស្តីបន្ទោសគេ ព្រោះតែការចងចាំរបស់ខ្ញុំនោះដែរ។

«ខ្ញុំសុំទោសបង! ខ្ញុំថាមិញនេះ ដោយសារខ្ញុំមើលបងឯងមិនស្គាល់! ផ្ទះនេះឧស្សាហ៍ត្រូវពួកកម្មករលបឡើងមកពេលមានកម្មវិធី ហើយលួចរបស់របរទៅ ចៅកែស្តីបន្ទោសខ្ញុំរហូត!»

«ឯងមកស្រុកខ្មែរ តែមិនដែលទៅលេងអញសោះ!»

ខ្ញុំនិយាយតិចៗ ដាក់ប្អូនប្រុសកាលពីអតីតកាលរបស់ខ្ញុំ។ ជាប្អូនដែលខ្ញុំចងចាំមុខតូចច្រម៉ក់របស់វានៅក្នុងចម្រឹងបង្អួច ដែលម្តាយវាចាក់សោទុកចោលហើយទៅលេងល្បែង។

ពេលនេះខ្ញុំសឹងតែភ្លេចថា វាក្លាយទៅជាជំនួយការរបស់ អ្នកឧកញ៉ាល្បីម្នាក់ ហើយថែមទាំងមិនដឹងផងថា មេដ៏អស្ចារ្យរបស់វា ជាម្ចាស់ផ្ទះដែលជប់លៀងផងស្រវឹងគប់គ្នាផងនេះ។

«ខ្ញុំតាមរកបងឯងយូរហើយ!»

«រកមានការអី? ៨ឆ្នាំហើយ អ្ហែងសូម្បីសរសេរសំបុត្រមកអញមួយក៏គ្មានផងអាម៉ាច!»

ថាចប់ខ្ញុំដើរចោលវាលឿនស្លុយចុះមកក្រោមវិញ ហើយវាក៏មិនបានតាមខ្ញុំមកដែរ។

ដែលខ្ញុំនិយាយគំរោះគំរើយដាក់វា ដោយសារតែខ្ញុំដឹងថា ម៉ាចតែងតែព្យាយាមគេចមុខពីខ្ញុំពេលវិលមកភ្នំពេញវិញក្នុងនាមបណ្ឌិត។ រឿងនេះប្រហែលព្រោះខ្លាចថាមិត្តភក្តិ អ្នករៀនជាមួយវា ឬអ្នកដែលបាននឹងកំពុងហែហមឆ្វេងស្តាំវា ដឹងថាលោកបណ្ឌិតធ្លាប់មានបងប្រុសម្នាក់ ដែលប្រកបរបរមិនច្បាស់លាស់ គ្មានអាជីពវិជ្ជាជីវៈល្អៗដូចវា។

ទីបំផុតទៅខ្ញុំគេចពីអាម៉ាចមិនបានប៉ុន្មានទេ ព្រោះថាបើមនុស្សមានបំណងពិតប្រាកដ អ្វីក៏មិនអាចរារាំងវាក្នុងការមករកខ្ញុំទាល់តែបានជួបគ្នាស្ងាត់ៗដែរ។

នៅល្ងាចមួយពេលខ្ញុំកំពុងតែរៀបចំត្រឡប់ទៅផ្ទះបន្ទាប់ពីអង្គុយធ្វើសន្តិសុខយាមកាមពេញមួយថ្ងៃយ៉ាងហត់នឿយ ម៉ាចបានបង្ហាញខ្លួនដោយឡាន ទំនើបខ្មៅស្រិលរាប់ម៉ឺនដុល្លារ។

«បងយើងគួរតែផឹកជាមួយគ្នាម្តង!»

ប្អូនមកដល់ហើយ ទោះខឹងយ៉ាងណា ទោះបែកក្នាយូរយ៉ាងណា ការអង្គុយផឹកជាមួយគ្នាពេលនេះជារឿងល្អមួយកំដរបេះដូងកំព្រារបស់ខ្ញុំ។

យើងអង្គុយផឹកទល់មុខគ្នាក្នុងបៀរហ្គាឌិនមួយកន្លែង យូរក្រៃលបន្តិចទើបវារកឱកាសបាននិយាយពន្យល់ខ្ញុំថា ឪពុករបស់សាមីនដែលជាសេដ្ឋីគាត់មានជំងឺធ្ងន់ណាស់ ពេទ្យប្រាប់គ្រួសារថាអ្នកជំងឺដល់ដំណាក់កាលចុងក្រោយហើយ ដូច្នេះវាសំណូមពរខ្ញុំឱ្យជួយទៅនិយាយដណ្តឹងយកអាមីនឱ្យធ្វើជាប្រពន្ធវា។

ហេតុផលរបស់ម៉ាច គឺខ្លាចថា ដោយសារតែសាមីនមានសល់ទ្រព្យសម្បត្តិច្រើនពីឪធម៌ និងដោយសារនាងជាកូនទោលហើយប្រពន្ធគាត់លែងលះមានប្តីថ្មីបាត់ទៅហើយ តាំងពីនាងចូលនៅគ្រួសារនោះឪពុកនាងជឿហុងស៊ុយថា ខែឆ្នាំនាងត្រូវជាមួយគាត់ មានចំណូលនិងចំណេញទ្រព្យច្រើនសន្ធឹក ទើបនាងនៅតែជាកូនសំណព្វ រហូតដល់វេលាត្រូវស្នងមរតកបានចូលមកដល់។

មានមនុស្សជាច្រើនចង់បានសាមីនធ្វើជាភរិយាដោយសារតែរឿងទ្រព្យសម្បត្តិនោះ ហើយម៉ាចបន្លាចខ្ញុំថា អាមីននឹងជួបបញ្ហានៅក្នុងជីវិតព្រោះគំនិតអាក្រក់នៃប្រុសៗទាំងនោះ ដូច្នេះហើយវាគិតថា ខ្លួនវាដែលស្គាល់នាងតាំងពីនៅមណ្ឌលជើងចាប ទើបជាមនុស្សស័ក្តិសមបំផុតជាមួយអាមីន។

ម៉ាចសំណូមពរផង សន្យាផងថា វានឹងថែទាំ ជួយមើលខុសត្រូវអាមីនមិនឱ្យមានបញ្ហាលំបាកទេជាមួយនឹងទ្រព្យសម្បត្តិដែលឪពុកនាងបន្សល់ទុក។

«ក្រៅពីល្ងង់ហើយត្រង់! ណាមួយអាមីនខ្លួនឯង ក៏មានសុខភាពខ្សោយទៀត! ឧស្សាហ៍ញ៉ាំថ្នាំងងុយគេង អ៊ីចឹងហើយហើយវាមានបញ្ហាតម្រងនោមរ៉ាំរ៉ៃ តែងតែចេញទៅបរទេសព្យាបាលរហូត! បើបងឯងឱ្យវាមានជីវិតរស់នៅឯកោ ម្នាក់ឯង ដូចមិនរវល់នឹងវាអ៊ីចឹង!»